**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ...០៣៤...គ.ល

ថ្ងៃ ៧ ៦ កើត ខែ... ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...២០... ខែ...កុម្ភៈ ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុលអគារ C របស់ទីស្តីការក្រសួង និងការងារជួសជុលអគារស្នាក់នៅរបស់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាគ្រឿងញៀន ស្ថិតនៅភូមិឆ្លក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហ គ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុលអគារ C របស់ទីស្តីការក្រសួង និងការងារជួសជុលអគារស្នាក់នៅរបស់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាគ្រឿងញៀនស្ថិតនៅភូមិឆ្លក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បី ចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋាន អគារលេខ៧៨៨ មហាវិថីមុនីវង្សរាជធានីភ្នំពេញចាប់ពីថ្ងៃទី...៥...ខែ...មករា...ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរសព្ទទាក់ទងលេខ ០២៣ ២១៤ ៩៧០)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី...៦..... ខែ...កុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង...........៨:៣០......................។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង...៨:៣០... ថ្ងៃទី...៦........ខែ...កុម្ភៈ...ឆ្នាំ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**វង សូត**

ចម្លងជូន:

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ